ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន



# គ្រាដ៏អស្ចារ្យសម្រាប់ព្រះយេស៊ូ

និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Sarah S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

កាលព្រះយេស៊ូបានទទួល
ពិធីជ្រមុជទឹករួចហើយ,
ព្រះជាម្ចាស់បានមានព្រះ
បន្ទូលទៅកាន់ព្រះអង្គ។
ព្រះជាម្ចាស់មានព្រះ
បន្ទូលថា ៖ “នេះជាបុត្រដ៏
ជាទីស្រឡាញ់របស់យើង
យើងគាប់ចិត្តនឹងប្រុះអង្គ
ណាស់”។ ព្រះវិញ្ញាណដ៏
វិសុទ្ធរបស់ព្រះជាម្ចាស់
មានសណ្ឋានដូចសត្វ
ព្រាប បានយាងចុះមក
សណ្ឋិតលើព្រះយេស៊ូ។



ពេលនោះ ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ បាននាំព្រះយេស៊ូទៅវាលរហោស្ថាន ហើយព្រះអង្គគង់នៅទីនោះតែមួយអង្គឯង។



ព្រះយេស៊ូបានតមអាហាររយៈពេលសែសិបថ្ងៃ។
គឺព្រះអង្គពុំបានសោយអ្វីសោះឡើយ។ ដូច្នេះ
ហើយព្រះអង្គឃ្លាន។



ព្រះគម្ពីរបានចែងថា នៅទីរហោស្ថាននោះ
ក៏មានសត្វព្រៃជាច្រើនផងដែរ។



មារសាតាំងក៏បានចូលមកល្បួងព្រះយេស៊ូ។
វាធ្លាប់បានល្បួងលោកអាដាំ និង លោកស្រីអេ
វ៉ានៅក្នុងសួនអេដែន ឲ្យមិនស្ដាប់បង្គាប់ព្រះ
ជាម្ចាស់ កាលគ្រាកន្លងទៅនោះដែរ។ ពេល
នេះ វាក៏បានមកល្បួងលរព្រះយេស៊ូវិញម្ដង។





មារសាតាំង
បានព្យាយាមល្បួង សូម្បីព្រះ
យេស៊ូជព្រះបុត្រារបស់ព្រះ
ជាម្ចាស់ក៏ដោយ។

មារសាតាំងនិយាយថា ៖ “ប្រសិនបើលោកពិតជា
ព្រះបុត្រារបស់ព្រះជាម្ចាស់មែន សូមធ្វើឲ្យដុំថ្មទាំង
នេះ ក្លាយទៅជានំបុ័ងមើល៍!”។ វាដឹងថា ព្រះ
យេស៊ូកំពុងឃ្លាន។ វាក៏ដឹងថា ព្រះបុត្រារបស់ព្រះ
ជាម្ចាស់ អាចធ្វើឲ្យដុំថ្មក្លាយជានំបុ័ងបាន។ តើព្រះ
យេ ស៊ូធ្វើតាមពាក្យរបស់មារសាតាំង ដែរទេ?



ព្រះយេស៊ូមិនបានធ្វើតាមការល្បួងរបស់មារសាតាំង។ ផ្ទុយមកវិញ ព្រះអង្គបានយកព្រះបន្ទូលរបស់ព្រះជាម្ចាស់មកឆ្លើយតប ចំពោះការល្បួងនោះវិញ។ ព្រះអង្គមានព្រះបន្ទូលថា ៖ “មនុស្សមិនមែនរស់ដោយសារតែអាហារ ប៉ុណ្ណោះទេ គឺរស់ដោយសារ គ្រប់ព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ”។



ក្រោយមកទៀត មារសាតាំងបាននាំព្រះយេស៊ូចូលទៅចំណុចដ៏សំខាន់នៃទីក្រុងយេរូសាឡឹម គឺទៅព្រះវិហារ ដែលមានមនុស្ស បានថ្វាយបង្គំព្រះជាម្ចាស់។ តើមារសាតាំង នឹងធ្វើអ្វីបន្ទាប់ទៀត?



មារសាតាំង ទូលព្រះអង្គថា ៖ “ប្រសិនបើលោកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន សូមលោតទម្លាក់ខ្លួនចុះទៅក្រោមមើល៍ ដ្បិតក្នុងគម្ពីរមានចែងថា ព្រះជាម្ចាស់នឹងបញ្ជាឲ្យទេវតាចាំទ្រលោក មិនឲ្យជើងលោកប៉ះទង្គិចនឹងថ្មឡើយ”។



ព្រះយេស៊ូបានឆ្លើយតបថា ៖ “ក្នុងគម្ពីរមានចែងថា
កុំល្បងលព្រជាម្ចាស់របស់អ្នកឡើយ”។





មារសាតាំង ក៏បានសាកល្បងម្ដងទៀត។
មារបាននាំព្រះយេស៊ូ ទៅលើកំពូលភ្នំមួយយ៉ាងខ្ពស់។

មារសាតាំងបានបង្ហាញឲ្យព្រះអង្គនគរទាំងប៉ុន្មាននៅក្នុងភិពពលោក និង ឲ្យព្រះអង្គឃើញភោគទ្រព្យរបស់នគរទាំងនោះផង។ មារទូលព្រះអង្គថា ៖ “ប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ ខ្ញុំនឹងប្រគល់សម្បត្តិនេះឲ្យ!”។



ព្រះយេស៊ូបញ្ជាវាថា ៖ “សាតាំងអើយ ចូរថយចេញទៅ ដ្បិតក្នុងគម្ពីរមានចែងថា អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គមួយប៉ុណ្ណោះ!”។



ពេលនោះ មារសាតាំង ក៏ចាកចេញ
ពីព្រះអង្គទៅ។ បន្ទាប់មកទៀត ក៏
មានហេតុការដ៏អស្ចារ្យបានកើត
ឡើង។ ព្រះជាម្ចាស់បាន
ចាត់ពួកទេវតាឲ្យមកគាល់
និង បម្រើព្រះ
យេស៊ូដែលជាព្រះ
បុត្រារបស់ព្រះអង្គ
ដែលមិនព្រមស្ដាប់
បង្គាប់តាមមារ
សាតាំង។



គ្រាដ៏អស្ចារ្យសម្រាប់ព្រះយេស៊ូ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាថាយ ៤, លូកា ៤

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថា
ជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្ដីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើង
ខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោស
នោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅ
ស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះ
អំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់
ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ
ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគត
ជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូម
ទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់
ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូល
បង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់
ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាមែន។

សូមអានព្រះគុម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យូហាន ៣៖១៦